# ក្រសួងការបរទេសសហរដ្ឋអាមេរិកចេញផ្សាយរបាយការណ៍ស្តីពីភេរវកម្មប្រចាំឆ្នាំ២០០៦

របាយការណ៍តាមប្រទេសនីមួយៗស្តីពីភេរវកម្មប្រចាំឆ្នាំ២០០៦ គឺជារបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលកំណត់ដោយច្បាប់របស់សហរដ្ឋអាមេរិក អោយខ្លួនធ្វើការវាយតំលៃពីស្ថានភាពភេរវកម្មអន្តរជាតិ ដោយក្នុងនោះរួមមានការរៀបរាប់ពីកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលបរទេសនៃប្រទេសនីមួយៗ ស្តីពីសង្គ្រាមប្រឆាំងអំពើភេរវកម្ម ។ របាយការណ៍នេះ បង្ហាញពីព្រឹត្តិការណ៍នានា ដែលកើតមានឡើងចាប់ពីខែមករា រហូតដល់ខែ ធ្នូ ឆ្នាំ២០០៦ ។

ផ្នែកមួយនៃរបាយការណ៍នេះស្តីពីប្រទេសកម្ពុជា គឺមានភ្ជាប់មកដូចខាងក្រោម ។ សំរាប់អ្នកសារពត៌មានដែលចង់សួរសំណួរស្តីពីរបាយការណ៍នេះ សូមទាក់ទងមកកាន់ការិយាល័យកិច្ចការសាធារណៈ នៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ។ របាយការណ៍ទាំងមូលស្តីពីភេរវកម្ម អាចបើកមើលឃើញនៅលើគេហទំព័ររបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលមានអាស័យដ្ឋានៈ http://www.state.gov/s/ct/rls/crt/

## របាយការណ៍ស្តីពីភេរវកម្មសំរាប់ប្រទេសកម្ពុជា

លទ្ធភាពរបស់ប្រទេសកម្ពុជាក្នុងការស៊ើបអង្កេតសកម្មភាពបង្កគ្រោះថ្នាក់របស់ភេរវករ នៅមានកំរិតនៅឡើយ ដោយសារកង្វះខាតការបណ្តុះបណ្តាល និងធនធានផ្សេងៗ ។ ការមិនមានច្បាប់គ្រប់គ្រាន់ក្នុងប្រទេសសំរាប់ប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ក៏ជាឧបសគ្គមួយដែរដល់លទ្ធភាពរបស់រាជរដ្ឋាភិបាល ក្នុងការចាប់និងកាត់-ទោសក្រុមភេរវជន ។ ទោះជាយ៉ាងណាក៏ដោយ អ្នកដឹកនាំនយោបាយរបស់ប្រទេសកម្ពុជា បានបង្ហាញអោយឃើញនូវការតាំងចិត្តយ៉ាងខ្លាំងក្លា ក្នុងការចាត់វិធានការតាមផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងក្រុមភេរវករ ។

កន្លងមក មិនមានសញ្ញាណាមួយដែលបង្ហាញថា មានក្រុមភេរវជនធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជាទេ តែព្រំដែនដែលមានចន្លោះប្រហោងនិងអំពើពុករលួយដែលមានជាទូទៅ ងាយធ្វើអោយប្រទេសនេះមានវត្តមានរបស់ភេរវករ ។ រដ្ឋាភិបាលកម្ពុជាជឿថា ពួកអ្នកប្រយុទ្ធដើម្បីសេរីភាពកម្ពុជា (CFF) ដែលបានធ្វើការវាយប្រហារដោយអាវុធកាលពីខែវិច្ឆិកា ឆ្នាំ ២000 ហើយដែលបានសំលាប់មនុស្សអស់៨ នាក់នោះ នៅតែអាចធ្វើការវាយប្រហារក្នុងប្រទេសកម្ពុជាដែរ ។ មេដឹកនាំរបស់ក្រុមនេះត្រូវបានចាប់ខ្លួននៅរដ្ឋ California ក្នុងសហរដ្ឋ-អាមេរិក ក្នុងឆ្នាំ ២00៥ ។ រដ្ឋាភិបាលកម្ពុជាបានធ្វើការជាមួយការិយាល័យស៊ើបអង្កេតសហព័ន្ធ(FBI) ដើម្បីចាប់ខ្លួនមេដឹកនាំCFF ទៅកាត់ទោសនៅសហរដ្ឋអាមេរិក ។

មន្ត្រីមួយចំនួនត្រូវបានតែងតាំងអោយកាន់មុខនាទី នៅក្នុងគណៈកម្មាធិការជាតិកម្ពុជាប្រឆាំងអំពើភេរ-វកម្ម (NCTC) ដែលជាក្រុមមួយអាចធ្វើការសំរេចលើគោលនយោបាយ និងត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២00៥ ដោយរាជរដ្ឋាភិបាលកម្ពុជា ហើយដែលមានសម្តេចនាយករដ្ឋមន្ត្រីធ្វើជាប្រធាន ។ ផ្នែកយោធារបស់ប្រទេស

អូស្ត្រាលីបានធ្វើសន្និសីទមួយជាមួយ NCTC ក្នុងខែសីហា ហើយបានសំដែងបំណងចង់ធ្វើការងារបន្តដោយប្រជុំពិភាក្សាជាមួយ NCTC ។

ក្រៅពីការផ្តល់ជំនួយសំរាប់ NCTC រដ្ឋាភិបាលអូស្ត្រាលីបានជួយកម្ពុជាក្នុងការធ្វើពង្រាងច្បាប់ថ្មីប្រឆាំងអំពើភេរវកម្ម ។ ពង្រាងច្បាប់នេះត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការនិតិកម្មដែលមានការពាក់ព័ន្ធ ហើយគេរំពឹងថា រដ្ឋសភាជាតិនឹងផ្តល់ការអនុវម័តទៅលើច្បាប់នេះ ។ រដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋាភិបាលចក្រភពអង់-គ្លេស បានរួមគ្នាឧបត្ថម្ភបើកធ្វើសិក្ខាសាលាថ្នាក់ជាតិមួយស្តីពីការប្រឆាំងអំពើភេរវកម្មកាលពីខែមេសា ដើម្បីជួយបណ្តុះបណ្តាលដល់ក្រុមយោធានិងនគរបាលកម្ពុជា ។ រដ្ឋាភិបាលប្រទេសម៉ាឡេស៊ី បានធ្វើកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជាលើករណីទាក់ទងនឹងប្រទេសម៉ាឡេស៊ី ។

ក្នុងខែធ្នូ បន្ទាប់ពីទស្សនៈកិច្ចរបស់នាយករដ្ឋមន្ត្រីស្រីឡាំងកាមក រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថាមន្ត្រីស៊ើបការសំងាត់ផ្នែកយោធាម្នាក់របស់ប្រទេសស្រីឡាំងកា នឹងធ្វើការជាមួយមន្ត្រីយោធានិងមន្ត្រីនគរបាលកម្ពុជា ស្តីពីការផ្តល់ពតិមានសំងាត់ ។ ការប្រកាសនេះត្រូវបានធ្វើឡើងបន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធា-នាចំពោះសមភាគីស្រីឡាំងការបស់លោកថា ពួកឧទ្ទាមខ្លាទមិឡ នឹងមិនទទួលបានអាវុធរត់ពន្ធចេញពីកម្ពុជាទេ បើទោះបីជារដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា រឿងនេះប្រហែលជាបានកើតមានក្នុងពេលកន្លងមកក្តី ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាបានបំផ្លាញអាវុធធុនតូចអស់ជាង ២សែនដើម ដោយមានជំនួយពីសហគមន៍អឺរ៉ុប ហើយជាមួយជំនួយរបស់សហរដ្ឋអាមេរិក កម្ពុជាបានបំផ្លាញចោលកាំជ្រួចបាញ់ធុន MANPADS ពីឃ្លាំងរបស់ខ្លួន ។

ដោយមានជំនួយពីសហរដ្ឋអាមេរិក រាជរដ្ឋាភិបាលកម្ពុជាបានដំឡើងប្រព័ន្ធគ្រប់គ្រងព្រំដែនតាមប្រព័ន្ធកុំព្យូទ័រនៅព្រលានយន្តហោះនៅភ្នំពេញនិងខេត្តសៀមរាប និងនៅច្រកព្រំដែនគោកនៅប៉ោយប៉ែត និងខេត្តកោះកុង ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានធ្វើសហប្រតិបត្តិការយ៉ាងពេញលេញតាមសំណើសុំរបស់សហរដ្ឋអាមេរិក ក្នុងការតាមដានត្រួតពិនិត្យលើក្រុមភេរវជននិងអង្គការភេរវជន ដែលត្រូវបានគេកំនត់ថាជាអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ក្រុមភេរវជនផងដែរ ។

# # # #

U.S. Embassy, #1, Street 96, Watphnom; Phone: 023-728-258; Fax: 023-728-800; Email: chreav@state.gov